# សេចក្តីប្រកាសព័ត៌មាន

## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦

## មហោស្រពភាពយន្តជប៉ុនប្រចាំឆ្នាំ២០១៦

ស្ថានទូតជប៉ុនរួមសហការជាមួយ មូលនិធិជប៉ុន និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នឹងរៀបចំមហោស្រពភាពយន្តជប៉ុននៅកម្ពុជា ពីថ្ងៃទី០៥ ដល់ថ្ងៃទី០៩ ខែវិច្ឆិកាឆ្នាំ២០១៦ នៅរោងភាពយន្ត Major Cineplex (AEON) និងរោងភាពយន្ត Legendទួលគោក នាទីក្រុងភ្នំពេញ ព្រមទាំងរោងភាពយន្ត Platinum Cineplex ក្នុងខេត្តសៀមរាប។

មានភាពយន្តជាច្រើនប្រភេទដែលបានធ្វើការសម្រិតសម្រាំងនឹងដាក់បញ្ចាំងនៅរោងភាពយន្តធំៗនៅទីក្រុងភ្នំពេញនិងសៀមរាបដូចដែលបានជម្រាបជូនខាងលើ។ ភាពយន្តដែលបានសម្រិតសម្រាំងទាំងអស់រួមមាន ភាពយន្តគំនូរជីវចល ភាពយន្តបែបមនោសញ្ចេតនា ភាពយន្តឯកសារ ភាពយន្តបែបសើបអង្កេត ហើយក្នុងនោះមានខ្សែភាពយន្តខ្លះក៏ធ្លាប់បានទទួលពានរង្វាន់ផងដែរ ដែលភាពយន្តទាំងនោះក៏បានឆ្លុះបញ្ចាំងអំពីជីវិតរស់នៅរបស់ជនជាតិជប៉ុន សង្គម និងវប្បធម៌ជប៉ុន ហើយមហោស្រពនេះក៏ផ្តល់ឱកាសដ៏ល្អមួយសម្រាប់អ្នកទស្សនាដើម្បីអាចស្គាល់អំពីប្រទេស និងប្រជាជនជប៉ុន។ ការចូលរួមដោយសេរី!

ភាពយន្តជប៉ុនចំនួន១០រឿងនឹងត្រូវបានចាក់បញ្ចាំងជាមួយចំណងជើងរងជាភាសាខ្មែរនិងភាសាអង់គ្លេស។ កម្មវិធីលម្អិតនៃការចាក់បញ្ចាំងនឹងមានផ្សព្វផ្សាយនៅលើគេហទំព័រនៃមហោស្រពភាពយន្តជប៉ុន និងទំព័រហ្វេសប៊ុកដែលមានអាសយដ្ឋានដូចខាងក្រោម៖

http://kh.japanesefilmfest.org

https://www.facebook.com/jffcambodia

ការចូលរួមដោយសេរី ហើយកន្លែងអង្គុយនឹងផ្តល់អទិភាពជូនភ្ញៀវដែលអញ្ជើញមកដល់មុន។ ចំពោះព័តមានលម្អិតនៃការចាក់បញ្ចាំង សូមចូលទៅកាន់កម្មវិធីដូចដែលមានភ្ជាប់។

ចំពោះសំណួរផ្សេងៗ  សូមទាក់ទងមកកាន់ផ្នែកវប្បធម៌និងព័ត៌មាននៃស្ថានទូតជប៉ុនតាមរយៈ ទូរស័ព្ទលេខ០២៣ ២១៧ ១៦១ ឬក៏ផ្ញើអ៊ីម៉េលមកកាន់អាស័យដ្ឋាន info.jpn@pp.mofa.go.jp ។

---